# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៦០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :-**

ធ្វើវិសោធនកម្មព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា២ ចំណុចទី ២ លេខរៀងទី ១២ ដោយកែសម្រួលផ្ទៃដី តំបន់ដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព ពីដីសរុបទំហំ ៤០២.៥០០ហិកតា មកនៅត្រឹម ៤០១.៤០២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ហិកតា។ ដូច្នេះ ផ្ទៃដីដែលត្រូវកាត់ចេញពីដែនជំរកសត្វព្រៃគូលេន-ព្រហ្មទេព មានទំហំ ១.០៩៨ហិកតា ដូចមានផែនទីព្រំប្រទល់ និងនិយាមកាជូនភ្ជាប់ក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ២ :-**

ធ្វើការកែសម្រួលផ្ទៃដីទំហំ ១.០៩៨ហិកតា ដែលបានធ្វើវិសោធនកម្មកាត់ចេញពីផ្ទៃដីដែនជំរកសត្វព្រៃគូលេន ព្រហ្មទេព ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ប្រគល់អាណត្តិកាន់កាប់ជូនក្រសួងការពារជាតិ( អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ)ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

**មាត្រា ៣ :-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៤០៩.៤២៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៤២៣ ច.ល

ចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ស៊ុំ ម៉ានិត**

ឧស/រកត/០៤០៩/៤៦០

## ឧបសម្ព័ន្ធនៃ ព្រះរាជក្រឹត្យលេខ.............. ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៩




ROYAUME DU CAMBODGE • ROYAL • LE MINISTRE DU PALAIS ROYAL

**សញ្ញាសំគាល់**

- ផ្ទៃដីត្រូវកាត់ចេញពីតំបន់ការពារ ដែនជំរកសត្វព្រៃគូលេន ព្រហ្មទេព
- ផ្លូវ
- ផ្លូវទឹក
- ខ្សែរយៈកំពស់
- តំបន់ការពារ

N
W E
S

មាត្រដ្ឋាន ១ : ៣០ ០០០

0.៥ 0 0.៥ គ.ម

4/4h.